កិច្ចព្រមព្រៀងចម្បងសម្រាប់អតិថិជន សម្រាប់

ក្រុមហ៊ុន រ៉ូយ៉ាល់ក្រុប ហ្វាន់ ៦.ក

បានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៦

កិច្ចព្រមព្រៀងអតិថិជនស្តីពីសម្រាប់គម្រោងវិនិយោគរួម

ស្តីពីទម្រង់កិច្ចព្រមព្រៀងអតិថិជនសម្រាប់ការវិនិយោគលើមូលនិធិនៃគោលការណ៍ណែនាំលេខ ០៤៧/២៤ ន.ម.ក/គ.ណ.ន. ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការបើកគណនី និងទម្រង់សម្រាប់ការវិនិយោគលើមូលនិធិនៃគម្រោងវិនិយោគរួមកិច្ចព្រមព្រៀងអតិថិជនសម្រាប់ការវិនិយោគលើមូលនិធិ

ប្រការ ១៖ និយមន័យ

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ៖ សំដៅដល់បុគ្គលគ្រប់គ្រងមូលនិធិជានិតិបុគ្គលដែលត្រូវទទួលបានអាជ្ញាបណ្ណពី ន.ម.ក. ដើម្បីធ្វើអាជីវកម្មដូចមានកំណត់ក្នុងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម។

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស៖ សំដៅដល់ក្រុមហ៊ុនដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រាក់ ឬទ្រព្យសម្បត្តិជំនួសបុគ្គលមួយ ឬបុគ្គលមួយក្រុមដទៃទៀត។

ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង៖ សំដៅដល់ក្រុមហ៊ុនដែលត្រូវទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតពី ន.ម.ក. ដើម្បីធ្វើអាជីវកម្មចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ដូចមានកំណត់ក្នុងអនុក្រឹត្យ និងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម។

ភ្នាក់ងារចែកចាយលក់មូលនិធិ៖ សំដៅដល់រូបវន្តបុគ្គលដែលត្រូវទទួលបានអាជ្ញាបណ្ណពី ន.ម.ក. ដើម្បីផ្តល់សេវា និងធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ដូចមានកំណត់ក្នុងអនុក្រឹត្យ និងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម។

ឯកតាមូលនិធិ៖ សំដៅដល់ចំណែកនៃផលប្រយោជន៍របស់អ្នកកាន់កាប់ឯកតាមូលនិធិក្នុងគម្រោងវិនិយោគរួម។

បញ្ជីមូលនិធិ៖ សំដៅដល់បញ្ជីឈ្មោះមូលនិធិនៃគម្រោងវិនិយោគរួមដែលក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ទទួលបានសិទ្ធិក្នុងការចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ដោយមានព័ត៌មានចំណាត់ថ្នាក់ហានិភ័យនៃមូលនិធិនីមួយៗ សម្រាប់អតិថិជន។

គម្រោងវិនិយោគរួម៖ សំដៅដល់គម្រោងវិនិយោគដែលត្រូវទទួលបានការអនុញ្ញាតពី ន.ម.ក. និងមានលក្ខណៈដូចខាងក្រោម៖

(១) ការប្រមូលសាច់ប្រាក់ ឬ វត្ថុមានតម្លៃតាមរយៈការបោះផ្សាយលក់ឯកតាមូលនិធិ ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិក បូករួមទាំងក្រោដហ្វាន់ឌីង ឬតាមទម្រង់ផ្សេងទៀតដែលទទួលបានការអនុញ្ញាតពី ន.ម.ក. ដើម្បីបង្កើតមូលនិធិសាធារណៈ មូលនិធិឯកជន ឬបរធនវិនិយោគអចលនវត្ថុ ដូចដែលកំណត់ក្នុងប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម។

(២) រាល់សាច់ប្រាក់ ឬវត្ថុមានតម្លៃដែលប្រមូលបាន ត្រូវបានយកទៅប្រើប្រាស់ និងចាត់ចែងដោយក្រុមហ៊ុនគ្រប់គ្រងមូលនិធិនៅក្នុងគម្រោងវិនិយោគរួម ដើម្បីបង្កើតផលកម្រៃហិរញ្ញវត្ថុ ឬផលកម្រៃដែលបានមកជាសិទ្ធិ ឬជាផលប្រយោជន៍លើទ្រព្យសម្បត្តិ សម្រាប់សមាជិកដែលមានផលប្រយោជន៍ក្នុងគម្រោងវិនិយោគនោះ ទោះបីសមាជិកនោះមិនគ្រប់គ្រងលើប្រតិបត្តិការប្រចាំថ្ងៃនៃគម្រោងវិនិយោគនោះក៏ដោយ។

(៣) ទ្រព្យសម្បត្តិរបស់គម្រោងវិនិយោគរួមត្រូវរក្សាទុកដោយក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ដែលធ្វើប្រតិបត្តិការក្នុងនាមគម្រោងវិនិយោគរួម។

(៤) គម្រោងវិនិយោគរួមអាចជាមូលនិធិបើក ឬមូលនិធិបិទ។

(៥) គម្រោងវិនិយោគរួមអាចត្រូវបានគ្រប់គ្រងក្នុងទម្រង់ជាកិច្ចសន្យា ឬជាក្រុមហ៊ុន។

ប្រតិសិទ្ធិសកល៖ សំដៅដល់បុគ្គលដែលទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចទូទៅពីបុគ្គលដទៃ។

ប្រតិសិទ្ធិដោយឡែក៖ សំដៅដល់បុគ្គលដែលទទួលបន្តសិទ្ធិមួយ ឬច្រើនជាកំណត់ ផ្អែកតាមមូលហេតុនីមួយៗ។

ប្រការ ២៖ លក្ខខណ្ឌទូទៅ

២.១ អតិថិជនព្រមព្រៀងឱ្យក្រុមហ៊ុនបម្រើសេវាកម្មជាភ្នាក់ងាររបស់អតិថិជន និងមានសិទ្ធិក្នុងការធ្វើសកម្មភាពដែលទាក់ទងនឹងការវិនិយោគលើមូលនិធិដូចជា ការទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់ទៅវិញនូវឯកតាមូលនិធិ ការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិជាដើម។

២.២ ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការវិនិយោគលើមូលនិធិក្នុងគណនីអតិថិជនក្នុងនាមអតិថិជន ក្នុងទម្រង់ជាគណនីឆន្ទានុសិទ្ធិឡើយ។

២.៣ ក្រុមហ៊ុនធានាថា ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬការអនុញ្ញាតពី ន.ម.ក. ក្នុងការផ្តល់សេវាកម្មដល់អតិថិជន។

២.៤ ក្រុមហ៊ុនធានាថា ក្រុមហ៊ុនបានផ្តល់ជូនអតិថិជននូវតារាងថ្លៃសេវា កម្រៃជើងសា និងលាភការផ្សេងៗ ដែលទទួលបានការអនុញ្ញាតពី ន.ម.ក. មុននឹងអនុញ្ញាតឱ្យអតិថិជនធ្វើការវិនិយោគលើមូលនិធិ។ នៅពេលមានការផ្លាស់ប្តូរកម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗ ក្រុមហ៊ុនត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយសមស្របណាមួយអំពីការផ្លាស់ប្តូរនេះ។

២.៥ អតិថិជនយល់ព្រមផ្តល់ជូនក្រុមហ៊ុននូវ៖

(ក) ព័ត៌មានស្តីពីអត្តសញ្ញាណពិតប្រាកដរបស់អតិថិជន។

(ខ) ព័ត៌មានស្តីពីអត្តសញ្ញាណពិតប្រាកដរបស់បុគ្គលទទួលបានការអនុញ្ញាត បុគ្គលគ្រប់គ្រង និង បុគ្គលទទួលបានផលប្រយោជន៍ ប្រសិនមាន។

(គ) គោលដៅនៃការវិនិយោគរបស់អតិថិជន។

២.៦ ក្រុមហ៊ុនត្រូវផ្តល់ជូនអតិថិជននូវរបាយការណ៍ស្តីពី ប្រតិបត្តិការនៃការវិនិយោគលើមូលនិធិរបស់អតិថិជន តាមការស្នើសុំរបស់អតិថិជន តាមរយៈឯកសារជាលាយលក្ខណ៍អក្សរ សារអេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀតដែលត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអតិថិជន។

២.៧ ភាគីទាំងពីរព្រមព្រៀងថា ការវិនិយោគលើមូលនិធិត្រូវធ្វើឡើងអនុលោមតាមច្បាប់ និងបទប្បញ្ញតិជាធរមាន។

ប្រការ ៣៖ ការវិនិយោគលើមូលនិធិ

៣.១ អតិថិជនត្រូវប្រាកដថា បានអាន និងយល់ច្បាស់ពីច្បាប់ បទប្បញ្ញត្តិ និងឯកសារពាក់ព័ន្ធនឹងមូលនិធិ នៃគម្រោងវិនិយោគរួមដែលត្រូវវិនិយោគ ព្រមទាំងលក្ខខណ្ឌទូទៅនៃការវិនិយោគលើមូលនិធិ មុននឹងធ្វើការយោគលើមូលនិធិ។

៣.២ ក្រុមហ៊ុនត្រូវប្រាកដថា សាច់ប្រាក់ និងទ្រព្យសម្បត្តិរបស់អតិថិជន ដែលពាក់ព័ន្ធនឹងការវិនិយោគលើមូលនិធិត្រូវបានផ្ទេរ ឬបញ្ជូនទៅគណីសាច់ប្រាក់ និង/ឬសម្បត្តិរបស់មូលនិធិនៃគម្រោងវិនិយោគរួមដែលស្ថិតនៅក្រោមការថែរក្សាដោយក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ដែលទទួលបានអាជ្ញាបណ្ណពី ន.ម.ក។

៣.៣ អតិថិជនត្រូវយល់ដឹងឱ្យច្បាស់ពីលក្ខខណ្ឌពាក់ព័ន្ធនឹងការទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ និងការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិ អនុលោមតាមឯកសារផ្តល់ព័ត៌មាននៃមូលនិធិ នៃគម្រោងវិនិយោគរួមនីមួយៗ។

៣.៤ ការទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ និងការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិអាចធ្វើឡើងតាមរយៈឯកសារជាលាយលក្ខណ៍អក្សរ ទូរសព្ទ សារអេឡិចត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀត។ ក្រុមហ៊ុនត្រូវធានាឱ្យមាននូវយន្តការប្រកបដោយប្រសិទ្ធភាពក្នុងការទទួលបញ្ជាទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ និងការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិ ពីអតិថិជន។

៣.៥ ក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានដល់អតិថិជនទាក់ទងនឹងហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងពាក់ព័ន្ធនឹងការវិនិយោគលើមូលនិធិរបស់អតិថិជន និងក្រុមហ៊ុនត្រូវទទួលខុសត្រូវលើហានិភ័យនៃការអាក់រអួលប្រព័ន្ធទូរសព្ទ អ៊ីនធឺណិត ឬប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុន ក្នុងពេលទទួលបញ្ជាទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ និងការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិ ពីអតិថិជន។

៣.៦ ក្រុមហ៊ុនត្រូវធានាកាត់បន្ថយជាអតិបរមានូវហានិភ័យ ដែលអាចកើតមានឡើងពាក់ព័ន្ធនឹងការបញ្ជាទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ និងការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិរបស់អតិថិជន។

៣.៧ ក្រុមហ៊ុនត្រូវជូនដំណឹងភ្លាមដល់អតិថិជន ក្នុងករណីក្រុមហ៊ុនដឹងថាមានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជាទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ និងការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិពីអតិថិជន ប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជន ដើម្បីដាក់បញ្ជាទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ និងការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិ។

៣.៨ អតិថិជនត្រូវជូនដំណឹងភ្លាមដល់ក្រុមហ៊ុន ក្នុងករណីអតិថិជនដឹងថាមានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជាទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ និងការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិ ប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជន ដើម្បីដាក់បញ្ជាទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ និងការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិ។

៣.៩ អតិថិជនត្រូវធ្វើការទូទាត់សាច់ប្រាក់វិនិយោគ ថ្លៃសេវា កម្រៃជើងសា ឱ្យបានត្រឹមត្រូវទៅក្រុមហ៊ុននៅពេលធ្វើការវិនិយោគ។

៣.១០ ក្រុមហ៊ុនត្រូវពិនិត្យ និប្រាកដថា ការទូទាត់សាច់ប្រាក់ជូនអតិថិជនវិញបានត្រឹមត្រូវ ក្នុងករណីដែលការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិរបស់អតិថិជនត្រូវបានអនុម័តយល់ព្រម។

៣.១១ ក្រុមហ៊ុនត្រូវផ្តល់ជូនអតិថិជននូវបញ្ជីមូលនិធិ នៅពេលបើកគណនីវិនិយោគលើមូលនិធិជូនអតិថិជន។ រាល់ពេលមានការធ្វើបច្ចុប្បន្នភាពលើបញ្ជីមូលនិធិ ក្រុមហ៊ុនត្រូវផ្តល់ជូនអតិថិជនភ្លាមនូវបញ្ជីមូលនិធិ ដែលត្រូវបានធ្វើបច្ចុប្បន្នភាពនោះមិនឲ្យលើសពី ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលបញ្ជីមូលនិធិត្រូវបានធ្វើបច្ចុប្បន្នភាព។

ប្រការ ៤៖ ការអនុវត្តការបញ្ជាទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ និងការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិ

៤.១ ក្រុមហ៊ុនត្រូវតែអនុវត្តការបញ្ជាទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ និងការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិរបស់អតិថិជនឱ្យបានត្រឹមត្រូវ ច្បាស់លាស់ ទាន់ពេលវេលា និងមិនលម្អៀង។

៤.២ ក្រុមហ៊ុនត្រូវបញ្ជូនការបញ្ជាទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ និងការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិភ្លាមទៅតាមកាលបរិច្ឆេទនៃការបញ្ជាទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ និងការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិ ដោយមិនត្រូវបង្អែរ ឬពន្យារពេលឡើយ។

ប្រការ ៥៖ ទិដ្ឋានការលើស្ថានភាពមិនប្រក្រតីរបស់អតិថិជន

ក្រុមហ៊ុនអាចផ្អាកការទទួលបញ្ជាទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ ការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិពីអតិថិជន ដោយត្រូវមានមូលហេតុច្បាស់លាស់ ក្នុងករណី៖

- អតិថិជនបានលាក់បាំង ឬផ្តល់ព័ត៌មានមិនពិត
- អតិថិជនមិនអនុវត្តតាមប្រការណាមួយនៃកិច្ចព្រមព្រៀងនេះ
- ការដាក់បញ្ជាទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ ការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិរបស់អតិថិជនមិនត្រឹមត្រូវ ឬអាចល្មើសច្បាប់ ឬ
- មានការតម្រូវពី ន.ម.ក.។

ប្រការ ៦៖ កត្តាហានិភ័យ

៦.១ អតិថិជនបានសិក្សា និងយល់ដឹងពីការទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ ការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិ យន្តការ និងការអនុវត្តការទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ ការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិ ការថែរក្សាទុកសាច់ប្រាក់របស់មូលនិធិនៃគម្រោងវិនិយោគរួម កត្តាហានិភ័យ និងព្យសនកម្មដែលជាលទ្ធផលបណ្តាលមកពីការទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ ការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិ។ អតិថិជនក៏បានយល់ដឹងពីសិទ្ធិកាតព្វកិច្ច និងការទទួលខុសត្រូវរបស់ភាគីនីមួយៗ នៅក្នុងកិច្ចព្រមព្រៀងនេះ។

៦.២ អតិថិជនបានសិក្សា យល់ដឹង និងទទួលស្គាល់ពីហានិភ័យពាក់ព័ន្ធនឹងការទិញឯកតាមូលនិធិ ការស្នើឱ្យទិញត្រឡប់មកវិញនូវឯកតាមូលនិធិ ការស្នើសុំផ្លាស់ប្តូរឯកតាមូលនិធិ។

៦.៣ មុនចុះហត្ថលេខាជាមួយអតិថិជន ភ្នាក់ងារចែកចាយលក់មូលនិធិដែលទាក់ទងជាមួយអតិថិជនបានពន្យល់ពីខ្លឹមសារនៃកិច្ចព្រមព្រៀងនេះដល់អតិថិជន និងបានពន្យល់លម្អិតអំពីវិធីសាស្ត្រនៃការដាក់បញ្ជាទាំងអស់ និងហានិភ័យដែលអាចកើតមានពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការដាក់បញ្ជានីមួយៗដល់

អតិថិជន។ ភ្នាក់ងារចែកចាយលក់មូលនិធិត្រូវផ្តល់ជូនអតិថិជននូវឯកសារផ្តល់ព័ត៌មានអំពីហានិភ័យ និងត្រូវពន្យល់លម្អិត អំពីហានិភ័យទូទៅដែលអាចកើតមានពាក់ព័ន្ធនឹងការវិនិយោគលើមូលនិធិ ដូចមានកំណត់ក្នុងសេចក្តីប្រកាស ទទួលស្គាល់ហានិភ័យ និងពន្យល់ពីធាតុដែលមានកំណត់នៅក្នុងទម្រង់វាយតម្លៃភាពសមស្របរបស់អតិថិជន។

ប្រការ ៧៖ ករណីប្រធានសក្តិ

ការអនុវត្តកិច្ចព្រមព្រៀងនេះអាចត្រូវបានផ្អាកក្នុងករណីប្រធានសក្តិដូចជា ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី សង្គ្រាម អគ្គិភ័យជាដើម។ ក្រុមហ៊ុន ឬអតិថិជនត្រូវជូនដំណឹងទៅភាគីម្ខាងទៀត ឬទៅវិញទៅមកអំពីករណីប្រធានសក្តិនោះ ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ គិតចាប់ពីថ្ងៃកើតមានប្រធានសក្តិ។ កិច្ចព្រមព្រៀងនេះនឹងត្រូវបានអនុវត្តឡើងវិញក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ បន្ទាប់ពីប្រធានសក្តិនោះត្រូវបានបញ្ចប់ ឬរយៈពេលសមស្របណាមួយដែលមានការព្រមព្រៀងរវាងគូភាគី។

ប្រការ ៨៖ ការជូនដំណឹង

ភាគីនីមួយៗត្រូវជូនដំណឹងភ្លាមដល់ភាគីម្ខាងទៀត នៅពេលមានការផ្លាស់ប្តូរអាសយដ្ឋាន ឬព័ត៌មាន សម្រាប់ទំនាក់ទំនងផ្សេងទៀតរបស់ខ្លួន។

ប្រការ ៩៖ ការដោះស្រាយការតវ៉ា

៩.១ អតិថិជនអាចដាក់ពាក្យតវ៉ាជាលាយលក្ខណ៍អក្សរមកក្រុមហ៊ុន ក្នុងករណីដែលក្រុមហ៊ុនមិនអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ។

៩.២ ក្រុមហ៊ុនត្រូវពន្យល់ និងទទួលដោះស្រាយការតវ៉ារបស់អតិថិជន ក្នុងរយៈពេល ៧ (ប្រាំពីរថ្ងៃ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យតវ៉ា។

៩.៣ ក្រុមហ៊ុនត្រូវណែនាំអតិថិជនអំពីនីតិវិធីបន្ទាប់ ក្នុងករណីដែលអតិថិជនមិនពេញចិត្តនឹងការសម្រេចរបស់ក្រុមហ៊ុន។

ប្រការ ១០៖ ការផ្លាស់ប្តូរកម្មសិទ្ធិនៃទ្រព្យសម្បត្តិរបស់អតិថិជន

អតិថិជនព្រមព្រៀងថា រាល់សិទ្ធិ និងកាតព្វកិច្ចដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវផ្ទេរទៅឱ្យប្រតិសិទ្ធិសាកល និងប្រតិសិទ្ធិដោយឡែក ក្នុងករណីមានការផ្លាស់ប្តូរកម្មសិទ្ធិនៃទ្រព្យសម្បត្តិរបស់អតិថិជន ដែលមាននៅក្នុងមូលនិធិនៃគម្រោងវិនិយោគរួមដែលកើតឡើងដោយប្រតិបត្តិនៃច្បាប់ ការទទួលមរណភាពរបស់អតិថិជន ក្សីយធន អសមត្ថភាព ដីកាតុលាការ ឬដោយហេតុផលណាមួយផ្សេងទៀត។ ក្នុងករណីនេះ ក្រុមហ៊ុន ត្រូវសម្របសម្រួលក្នុងការអនុវត្តការផ្លាស់ប្តូរកម្មសិទ្ធិនៃទ្រព្យសម្បត្តិរបស់អតិថិជននោះ។

ប្រការ ១១៖ ការកែប្រែលក្ខខណ្ឌនៃកិច្ចព្រមព្រៀង

១១.១ លក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ អាចត្រូវបានកែប្រែនៅពេលមានការយល់ព្រមរវាងគូភាគីទាំងសងខាង។

ប្រការ ១២៖ ការមិនមានអនុភាពអនុវត្តនៃកិច្ចព្រមព្រៀងផ្សេងទៀត

រាល់បទបង្ហាញ ឬសេចក្តីថ្លែងការណ៍ ឬកិច្ចព្រមព្រៀងផ្សេងទៀតដែលមានខ្លឹមសារផ្ទុយពីកិច្ចព្រមព្រៀងនេះ ទោះជាលាយលក្ខណ៍អក្សរ ឬក៏ផ្ទាល់មាត់រវាងភាគីទាំងសងខាង មិនមានអានុភាពអនុវត្តឡើយ។

ប្រការ ១៣៖ ការបញ្ចប់កិច្ចព្រមព្រៀង

១៣.១ ភាគីនីមួយៗមានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះគ្រប់ពេលវេលា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ ដល់ភាគីម្ខាងទៀត។

១៣.២ ភាគីទាំងពីរយល់ព្រមថា ការបញ្ចប់កិច្ចព្រមព្រៀងនេះ មិនប៉ះពាល់សិទ្ធិ និងកាតព្វកិច្ច ព្រមទាំងផលប្រយោជន៍ ដែលមិនទាន់អនុវត្តចប់របស់ភាគីនីមួយៗ ដែលមានមុនពេលបញ្ចប់កិច្ចព្រមព្រៀងនេះ។

សេចក្តីប្រកាសទទួលស្គាល់ហានិភ័យ

ទម្រង់សេចក្តីប្រកាសទទួលស្គាល់ហានិភ័យនៃគោលការណ៍ណែនាំលេខ ០៨៧/២៤ ន.ម.ក/ គ.ណ.ន ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការបើកគណនី និងទម្រង់សម្រាប់ការវិនិយោគលើមូលនិធិនៃគម្រោងវិនិយោគរួម

ការវិនិយោគលើមូលនិធិនៃគម្រោងវិនិយោគរួមអាចប្រឈមនឹងហានិភ័យ ដូចនេះ អតិថិជនត្រូវពិចារណាលើប្រភេទមូលនិធិនៃគម្រោងវិនិយោគរួមនីមួយៗ បទពិសោធន៍ និងប្រភពហិរញ្ញវត្ថុរបស់អតិថិជនផ្ទាល់ ដើម្បីប្រាកដថាអតិថិជនអាចធ្វើការវិនិយោគលើមូលនិធិនៃគម្រោងវិនិយោគរួមបាន។ ទោះបីជាអតិថិជនមានបទពិសោធន៍ក្នុងការវិនិយោគលើមូលនិធិនៃគម្រោងវិនិយោគរួមក៍ដោយ ក៍អតិថិជននៅតែត្រូវយល់អំពីហានិភ័យចម្បងៗពាក់ព័ន្ធនឹងការវិនិយោគរបស់ខ្លួនដូចខាងក្រោម៖

ប្រភេទ ១៖ ហានិភ័យទីផ្សារ

ការប្រែប្រួលនៃសេដ្ឋកិច្ច លក្ខខណ្ឌទីផ្សារហិរញ្ញវត្ថុ ឬគោលនយោបាយរបស់រាជរដ្ឋាភិបាល អាចប៉ះពាល់ដល់ថ្លៃមូលបត្រ ឬឧបករណ៍មូលដ្ឋាន (underlying instrument) ដែលវិនិយោគដោយមូលនិធិនៃគម្រោងវិនិយោគរួមនិងបណ្តាលឱ្យមានការប្រែប្រួលថ្លៃនៃឯកតាមូលនិធិ។

ប្រភេទ ២៖ ហានិភ័យឥណទាន

សមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួមអាចរងឥទ្ធិពលពីសមិទ្ធកម្ម ឬសមត្ថភាពនៃការធ្វើធុរកិច្ចរបស់ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល ឬក្រុមហ៊ុនធុរកិច្ចផ្សេងទៀតដែលវិនិយោគដោយមូលនិធិនៃគម្រោងវិនិយោគរួម។ ហានិភ័យឥណទានឆ្លុះបញ្ចាំងពីលទ្ធភាពរបស់ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុល ឬក្រុមហ៊ុនធុរកិច្ចផ្សេងទៀត ក្នុងការបំពេញកាតព្វកិច្ចហិរញ្ញវត្ថុរបស់ខ្លួន។

ប្រភេទ ៣៖ ហានិភ័យអត្រាការប្រាក់

ហានិភ័យនៃការប្រែប្រួលនៃអត្រាការប្រាក់អាចប៉ះពាល់ដល់ថ្លៃមូលបត្របំណុល ឬឧបករណ៍មូលដ្ឋាន និងដល់សមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។ នៅពេលដែលអត្រាការប្រាក់កើនឡើង ថ្លៃមូលបត្របំណុលនឹងធ្លាក់ចុះ ប៉ុន្តែនៅពេលដែលអត្រាការប្រាក់ធ្លាក់ចុះ ថ្លៃមូលបត្របំណុលនឹងកើនឡើង។

ប្រភេទ ៤៖ ហានិភ័យសន្ទនីយភាព

មូលបត្រ ឬឧបករណ៍មូលដ្ឋាន ដែលវិនិយោគដោយមូលនិធិនៃគម្រោងវិនិយោគរួមអាចមានកម្រិតសន្ទនីយភាពទាប ឬមិនមានសន្ទនីយភាពដោយសារការថយចុះនៃតម្រូវការ ឬកត្តាពាក់ព័ន្ធផ្សេងទៀតដែលអាចជះឥទ្ធិពលអវិជ្ជមានលើតម្លៃនៃទ្រព្យសកម្ម ការលក់ចេញនៃទ្រព្យសកម្ម និងសមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។

ប្រភេទ ៥៖ ហានិភ័យអត្រាប្តូរប្រាក់

ក្នុងករណីដែលការវិនិយោគរបស់មូលនិធិនៃគម្រោងវិនិយោគរួមពាក់ព័ន្ធនឹងប្រតិបត្តិការជារូបិយប័ណ្ណបរទេស តម្លៃនៃរូបិយប័ណ្ណបរទេសនោះអាចមានការប្រែប្រួល។ អត្រាប្តូរប្រាក់អាចធ្វើឱ្យតម្លៃនៃការវិនិយោគរបស់មូលនិធិនៃគម្រោងវិនិយោគរួម ឡើង ឬចុះ ហើយជះឥទ្ធិពលលើសមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។

ប្រការ ៦៖ ហានិភ័យបន្ថយប្បញ្ញត្តិ

ហានិភ័យទាក់ទងនឹងការប្រែប្រួល ឬការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងអភិបាលកិច្ចនៃទីផ្សារមូលដ្ឋានដែលត្រូវបានវិនិយោគដោយមូលនិធិនៃគម្រោងវិនិយោគរួម ឬនៃការគ្រប់គ្រងមូលនិធិនៃគម្រោងវិនិយោគរួម អាចធ្វើឱ្យមានភាពមិនច្បាស់លាស់ និងការប្រែប្រួលខ្លាំងនៃថ្លៃមូលបត្រ ឬឧបករណ៍មូលដ្ឋានដែលវិនិយោគដោយមូលនិធិនៃគម្រោងវិនិយោគរួម និងសមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។

ប្រការ ៧៖ ហានិភ័យនៃការអនុវត្តស្តង់ដាគណនេយ្យ

គោលនយោបាយគណនេយ្យនៅក្នុងប្រទេសនីមួយៗអាចមានភាពខុសគ្នា និងអាចមិនស្របតាមការអនុវត្តជាអន្តរជាតិ ហើយអាចបង្កឱ្យមានហានិភ័យក្នុងការវាយតម្លៃទ្រព្យសកម្ម និងតម្លាភាពនៃគណនេយ្យ និងអាចប៉ះពាល់ដល់សមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។

ប្រការ ៨៖ ហានិភ័យនៃការអនុវត្តកិច្ចសន្យា និងសមភាគី

ប្រទេសខ្លះមិនមានប្រព័ន្ធដែលមានប្រសិទ្ធភាពសម្រាប់ការផ្ទេរ និងការកំណត់ថ្លៃទ្រព្យសកម្មនោះទេ ដែលអាចនាំឱ្យមានការលំបាកក្នុងការអនុវត្តកិច្ចសន្យាជាមួយសមភាគី។ ការណ៍នេះអាចធ្វើឱ្យការអនុវត្តនៃកិច្ចសន្យាប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីនៃកិច្ចសន្យា និងសមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។

ប្រការ ៩៖ ហានិភ័យធុរកិច្ច

ហានិភ័យដែលកើតចេញពីស្ថានភាពធុរកិច្ច និងវិស័យពាក់ព័ន្ធ អាចជះឥទ្ធិពលលើប្រតិបត្តិការរបស់ក្រុមហ៊ុន ឬតម្លៃនៃឧបករណ៍មូលដ្ឋានដែលមានការពាក់ព័ន្ធជាមួយការវិនិយោគរបស់មូលនិធិនៃគម្រោងវិនិយោគរួម។ ការណ៍នេះអាចជះឥទ្ធិពលអវិជ្ជមានលើសមិទ្ធកម្មរបស់មូលនិធិនៃគម្រោងវិនិយោគរួម។

ប្រការ ១០៖ ហានិភ័យប្រទេស និងនយោបាយ

ហានិភ័យដែលកើតចេញពីអស្ថិរភាពសេដ្ឋកិច្ច សង្គម និងនយោបាយនៃប្រទេសដែលពាក់ព័ន្ធនឹងការវិនិយោគរបស់មូលនិធិនៃគម្រោងវិនិយោគរួម អាចជះឥទ្ធិពលលើថ្លៃនៃមូលបត្រ ឬឧបករណ៍មូលដ្ឋាន សន្ទនីយភាពទីផ្សារ លក្ខខណ្ឌទីផ្សារ អតិផរណា ឬអត្រាប្តូរប្រាក់នៅក្នុងប្រទេសនោះ ហើយអាចបណ្តាលឲ្យមូលនិធិនៃគម្រោងវិនិយោគរួមមិនអាចទទួលបានផលចំណេញតាមការរំពឹងទុក។